ព្រឹត្តិប័ត្រសារព័ត៌មាន　　　　　　　　　　　　　　　　　ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៥

# Maybank champions 13th Group Global CR Day, empowering over 20,000 lives worldwide

# ធនាគារ មេយប៊ែង ប្រារព្ធទិវាទំនួលខុសត្រូវសង្គមជាសកលលើកទី១៣ ដែលជួយដល់ប្រជាជនជាង២ម៉ឺននាក់ទូទាំងពិភពលោក

- *Over 241,000 lives impacted since inception, driving progress in sustainability, education and welfare across communities*
- ប្រជាជនសរុបជាង២៤១ ០០០នាក់ បានទទួលអត្ថប្រយោជន៍ចាប់តាំងពីពេលដែលកម្មវិធីចាប់ផ្តើមដំបូង តាមរយៈការជំរុញ ការអប់រំ និងសុខុមាលភាពនៅទូទាំងសហគមន៍ប្រកបដោយចីរភាព

និយោជិតធនាគារ មេយប៊ែងជាង១៨០០០នាក់ នៅទូទាំងពិភពលោកបានមករួមគ្នាប្រារព្ធកម្មវិធីលើកទី១៣ នៃទិវាទំនួលខុសត្រូវសង្គមជាសកលរបស់សម្ព័ព្ធធនាគារ មេយប៊ែង ដោយបាននាំមកនូវការផ្លាស់ប្តូរជាវិជ្ជមានសម្រាប់ប្រជាជនក្នុងសហគមន៍ជាង ២០០០០នាក់នៅទូទាំងបណ្តាញប្រតិបត្តិការរបស់ធនាគារ តាមរយៈការបន្តដើរតួនាទីយ៉ាងសកម្មក្នុងការជះឥទ្ធិពលជាវិជ្ជមានដល់ជីវភាពរស់នៅប្រជាជន និងបរិស្ថានតាមរយៈគំនិតផ្តួចផ្តើមប្រកបដោយចីរភាព។

ក្រោមប្រធានបទ «ឈានមុខគេក្នុងការផ្លាស់ប្តូរប្រកបដោយចីរភាព» ទិវាទំនួលខុសត្រូវសង្គមជាសកលរបស់សម្ព័ន្ធធនាគារ មេយប៊ែង គឺជាផ្នែកមួយ នៃកម្មវិធីស្ម័គ្រចិត្តរបស់បុគ្គលិក នៃសម្ព័ន្ធធនាគារ មេយប៊ែង ក្រោមគំនិតផ្តួចផ្តើមដែលមានឈ្មោះថា Cahaya Kasih (CK)។ គំនិតផ្តួចផ្តើមទំនួលខុសត្រូវ នេះបានអនុញ្ញាតឲ្យនិយោជិតទាំងអស់ចូលរួមជាមួយគ្នាក្នុងថ្ងៃតែមួយ ដើម្បីធ្វើការងារសង្គម ដែលផ្តល់ផលវិជ្ជមានបែបយូរអង្វែងដល់សហគមន៍ បរិស្ថាន និងការអប់រំ និងក្នុងការឈានទៅកាន់អនាគតប្រកបដោយចីរភាព។

ទិវាទំនួលខុសត្រូវសង្គមជាសកលរបស់សម្ព័ព្ធធនាគារ មេយប៊ែង នេះប្រព្រឹត្តិទៅពេញមួយថ្ងៃ ក្នុងគោលបំណងឱ្យនិយោជិតរបស់ធនាគារ មេយប៊ែង បានបង្ហាញពីការប្តេជ្ញាចិត្តរបស់ពួកគេ ចំពោះគំនិតផ្តួចផ្តើមទំនួលខុសត្រូវនេះ CK។ កម្មវិធីនេះ ត្រូវបានគេជឿថាជាកម្មវិធីសហគមន៍ដ៏ធំបំផុតលើពិភពលោកដែលរៀបចំដោយស្ថាប័នម៉ាឡេស៊ី ដែលធ្វើឡើងក្នុងពេលដំណាលគ្នា។

នៅក្នុងឆ្នាំនេះ គំនិតផ្តួចផ្តើមសរុបចំនួន ៩៦ ត្រូវបានអនុវត្តនៅទូទាំងសម្ព័ព្ធ។ គម្រោងទាំងនេះត្រូវបានធ្វើឡើង មិនត្រឹមតែនៅក្នុងប្រទេសម៉ាឡេស៊ីប៉ុណ្ណោះទេ ប៉ុន្តែក៏មាននៅតាមបណ្តាការិយាល័យផ្សេងៗរបស់យើងនៅតាមបណ្តាប្រទេសផងដែរ រាប់ចាប់ពីទីក្រុងញូវយ៉ក និងទីក្រុងឡុងដ៍ រហូតដល់ប្រទេសចិន និងទូទាំងតំបន់អាស៊ាន។ សកម្មភាពទាំងនេះបានបញ្ជាក់ពីការលះបង់ពេលវេលា និងកម្លាំងកាយចិត្តរបស់និយោជិតធនាគារ មេយប៊ែង ទាំងអស់ដើម្បីរួមគ្នាបង្កើតជាកម្លាំងចលករ នៃសេចក្តីល្អមួយនេះ។

គំនិតផ្តួចផ្តើមជាសកលនេះ គឺស្របទៅតាមការប្តេជ្ញាចិត្តប្រកបដោយជីវភាពរបស់ធនាគារ មេយប៊ែង ដែលរួមមានការលើកកម្ពស់ទៅដល់ការរស់នៅរបស់សហគមន៍ដែលមានចំនួន ២លានគ្រួសារនៅទូទាំងតំបន់អាស៊ានគិតត្រឹមឆ្នាំ២០២៥ និងការចូលរួម១លានម៉ោងលើកិច្ចផ្តួចផ្តើមប្រកបដោយចីរភាព និងការដាក់ដំណើរការគំនិតផ្តួចផ្តើមចំនួន១ពាន់ ដែលពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិនៅឆ្នាំ២០២៥។

លោកស្រី **Mazhatulshima Mohd Zahid** នាយិកា នាយកដ្ឋានធនធានមនុស្សរបស់សម្ព័ន្ធធនាគារ មេយប៊ែង មានប្រសាសន៍ថា ៖ «ទិវាទំនួលខុសត្រូវសង្គមជាសកលរបស់សម្ព័ន្ធធនាគារ មេយប៊ែង ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តឥតងាករេរបស់យើងក្នុងការផ្លាស់ប្តូរជីវភាព ការលើកកម្ពស់ការរស់នៅឲ្យកាន់តែប្រសើររបស់ប្រជាពលរដ្ឋក្នុងសហគមន៍ និងការការពារបរិស្ថាន ដែលស្របទៅតាមបេសកកម្មរបស់សម្ព័ន្ធធនាគារ មេយប៊ែង ក្នុងការផ្តល់នូវសេវាហិរញ្ញវត្ថុប្រកបដោយអរិយភាព ស្របតាមយុទ្ធសាស្ត្រ**M25+**។»

លោកស្រីបន្តថា៖ «តាមរយៈស្មារតី នៃកិច្ចសហប្រតិបត្តិការ និងភាពជាសហគមន៍ យើងនឹងបន្តបំពេញតួនាទីជាស្ថាប័នដែលឈានមុខគេ ក្នុងការអនុវត្តគំនិតផ្តួចផ្តើមលើកិច្ចទំនួលខុសត្រូវសង្គមធំបំផុតមួយនៅក្នុងតំបន់។ ស្របពេល នៃការបន្តតំណែងរបស់ប្រធានអាស៊ាន នៃ ប្រទេសម៉ាឡេស៊ី គំនិតផ្តួចផ្តើមនេះបានគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់យើងក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដែលប្រជាជន និង សហគមន៍កំពុងជួបប្រទះ។ តាមរយៈការអនុវត្តគំនិតផ្តួចផ្តើមដែលមានឥទ្ធិពលខ្ពស់នេះ យើងមានគោលបំណងលើកកម្ពស់ជីវភាពរស់នៅ របស់ប្រជាជន ពង្រឹងភាពធន់របស់សង្គម និងជំរុញការការពារបរិស្ថាននៅទូទាំងអាស៊ាន និងជុំវិញពិភពលោក។»

លោកស្រីបានបន្ថែមទៀតថា៖ «កម្មវិធីទំនួលខុសត្រូវ Cahaya Kasih នៅតែជាផ្នែកមួយដ៏សំខាន់ នៃកិច្ចខិតខំប្រឹងប្រែងស្ម័គ្រចិត្តរបស់ បុគ្គលិក ដែលត្រូវបានរចនាឡើងដើម្បីដោះស្រាយបញ្ហាជាក់ស្តែង និងជួយសហគមន៍ដែលខ្វះខាតឱ្យមានភាពរឹងមាំសម្រាប់អនាគត ហើយ បញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរបស់យើងក្នុងការបង្កើតការផ្លាស់ប្តូរប្រកបដោយចីរភាព និងរយៈពេលវែងផងដែរ។ វង្វិលជុំ នៃរចនាសម្ព័ន្ធរយៈពេលពីរឆ្នាំ អាចធ្វើឲ្យយើងយល់ពីផលប៉ះពាល់ ដែលមានភាពវិជ្ជមានកាន់តែស៊ីជម្រៅ តាមរយៈការលើកសមត្ថភាពដល់ប្រជាជន ការ បង្កើនសមិទ្ធផលដល់សហគមន៍ និងការជំរុញវឌ្ឍនភាពក្នុងតំបន់ពេញមួយឆ្នាំ។»

នៅប្រទេសកម្ពុជា បុគ្គលិកធនាគារ មេយប៊ែង ជាង ៤០០នាក់ បានមកជួបជុំគ្នានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលតម្បាញសូត្រ របស់ធនាគារ មេយប៊ែង នៅខេត្តតាកែវ និងខេត្តសៀមរាប។ មជ្ឈមណ្ឌលទាំងពីរនេះ គឺជាផ្នែកមួយ នៃកម្មវិធីស្ត្រី និងតម្បាញរបស់ធនាគារ មេយប៊ែង ដែលជាយុទ្ធសាស្ត្រសំខាន់មួយរបស់មូលនិធិធនាគារ មេយប៊ែង ដែលបានចាប់ផ្តើមតាំងពីឆ្នាំ ២០១៦ ដើម្បីថែរក្សាវាយនភណ្ឌប្រពៃណីខ្មែរ នៅទូទាំងតំបន់អាស៊ាន បង្កើនសមត្ថភាពស្ត្រីឲ្យមានជីវភាពប្រកបដោយចីរភាព និងលើកកម្ពស់ការចូលរួមផ្នែកហិរញ្ញវត្ថុនៅក្នុងសហគមន៍ ក្នុងតំបន់។

តាមរយៈគំនិតផ្តួចផ្តើមនេះ យើងបានដាំដើមមនជាង ២០០០ដើម ដើម្បីថែរក្សាប្រពៃណីតម្បាញសូត្រ ដែលក្នុងនោះមានកសិករ និងស្ត្រី តម្បាញច្រើនជាង ១០០នាក់ ដែលត្រូវបានបណ្តុះបណ្តាលជំនាញបន្ថែមជាមួយនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដើម្បីពង្រឹងជីវភាព និងឯករាជ្យភាពរបស់ពួកគេ ព្រមជាមួយនឹងកុមារជិត ១០០នាក់ ត្រូវបានចូលរួមក្នុងសកម្មភាពកីឡា ដើម្បីពង្រឹងស្មារតីជាក្រុម ទំនុកចិត្ត និងភាពរីករាយ។ កម្មវិធីនេះនៅតែបន្តបង្ហាញពីការប្តេជ្ញាចិត្តរបស់ធនាគារ មេយប៊ែង ចំពោះការផ្តល់ការគាំទ្រដល់ស្ត្រី ការអភិរក្សវប្បធម៌ និងការ លើកកម្ពស់សហគមន៍នៅប្រទេសកម្ពុជា។

លោកវ័ត្ន សោភ័ណ នាយកប្រតិបត្តិ និងជានាយកប្រចាំប្រទេស ធនាគារ មេយប៊ែង បានមានប្រសាសន៍ថា៖ «ទិវាទំនួលខុសត្រូវជាសកល នៅប្រទេសកម្ពុជា មិនមែនគ្រាន់តែជាកម្មវិធីស្ម័គ្រចិត្តប៉ុណ្ណោះទេ ប៉ុន្តែជាការធ្វើឲ្យគោលបំណង នៃគំនិតផ្តួចផ្តើមរបស់យើងក្លាយជាការពិត។ ទិវានេះ បានផ្តល់ឲ្យបុគ្គលិកធនាគារ មេយប៊ែង ទាំងមូលមានឱកាសឆ្លុះបញ្ចាំងអំពីរបៀបដែលអាជីវកម្ម និងសហគមន៍របស់យើងតភ្ជាប់គ្នា យ៉ាងជិតស្និទ្ធ ដើម្បីបង្កើតឥទ្ធិពលដែលនឹងមានសារៈសំខាន់ពីមួយថ្ងៃទៅមួយថ្ងៃ។ ខ្ញុំមានមោទនភាពចំពោះបុគ្គលិករបស់ធនាគារ មេយប៊េង ក្នុងការចូលរួមជាកម្លាំងជាធ្លុងមួយ ដោយក្តីស្រឡាញ់ និងការសាមគ្គី ដែលបង្ហាញពីស្មារតីក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុប្រកបដោយអរិយភាព។»

ដោយឡែក សមាជិកក្រុមប្រឹក្សាភិបាល គណៈកម្មាធិការប្រតិបត្តិ រួមជាមួយនឹងនិយោជិតនៅតាមបណ្តាទីតាំងផ្សេងៗ ក៏បានចូលរួមយ៉ាង សកម្មជាចំណែក នៃគំនិតផ្តួចផ្តើមមួយនេះ ដោយរួមគ្នាធ្វើសកម្មភាពដែលក្នុងនោះរួមមាន ការដាំដើមឈើ ការចែកជំនួយស្បៀងអាហារ ការ រៀបចំសិក្ខាសាលាអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការបណ្តុះបណ្តាលជំនាញ និងសកម្មភាពជាច្រើនផ្សេងទៀត។

ទិវាទំនួលខុសត្រូវសង្គមសកលរបស់សម្ព័ន្ធធនាគារ មេយប៊ែង ត្រូវបានផ្តួចផ្តើមឡើងជាលើកដំបូងនៅក្នុងឆ្នាំ២០១០ ដើម្បីរំឭកខួបប្រាំទសវត្សរ៍ នៃការផ្តល់សេវាកម្មហិរញ្ញវត្ថុរបស់ធនាគារ មេយប៊ែង។ ក្នុងព្រឹត្តិការណ៍ដំបូងបង្អស់នោះ មានបុគ្គលិកជាង ១០ ០០០នាក់ បាន ចូលរួម។ ចំនួនអ្នកចូលរួមដែលកាន់តែច្រើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ បានបញ្ជាក់ឱ្យឃើញពីស្មារតីសាមគ្គីភាពជាក្រុមដ៏រឹងមាំរបស់ និយោជិតយើង ដែលមានឆន្ទៈក្នុងការរួមគ្នាចូលរួមក្នុងកម្មវិធីស្ម័គ្រចិត្តលំដាប់សកលដ៏មានលក្ខណៈពិសេសមួយនេះ។

ទិវាទំនួលខុសត្រូវសង្គមសកលរបស់សម្ព័ន្ធធនាគារ មេយប៊ែង មានលក្ខណៈពិសេសខុសប្លែកពីគំនិតផ្តួចផ្តើមទំនួលខុសត្រូវសង្គមរបស់ ក្រុមហ៊ុន (CSR) ទូទៅ ត្រង់ថាគំនិតផ្តួចផ្តើមនេះផ្តើមចេញពីនិយោជិតដោយផ្ទាល់ និងប្រព្រឹត្តទៅពេញមួយឆ្នាំ ហើយមានការសម្របសម្រួលពីសម្ព័ន្ធធនាគារ មេយប៊ែង។ រាល់គំនិតផ្តួចផ្តើមនីមួយៗ ត្រូវបានរៀបចំឡើងដោយនិយោជិតរបស់ធនាគារ ដែលយល់ច្បាស់ពីតម្រូវការរបស់សហគមន៍របស់ពួកគេ ដើម្បីធានាឲ្យបាននូវភាពពិតប្រាកដ និងចីរភាព។ ដោយមានការគាំទ្រពីមូលនិធិធនាគារ មេយប៊ែង និង នាយកដ្ឋានធនធានមនុស្ស នៃសម្ព័ន្ធធនាគារ មេយប៊ែង កម្មវិធីនេះតែងតែបង្កើតបាននូវសមិទ្ធផលជាក់ស្តែងដែលអាចវាស់វែងបាន ដែល ធ្វើឱ្យកម្មវិធីនេះក្លាយជាចលនាស្ម័គ្រចិត្តរបស់បុគ្គលិកមួយ ដែលគ្រប់ជ្រុងជ្រោយ និងមានការសម្របសម្រួលល្អបំផុតនៅក្នុងតំបន់អាស៊ាន។

*******************

*For more information, please contact:*

***Maybank Group Corporate Affairs***
*Izlyn Ramli +60 19 200 0248/Wan Nazdy +6012 3517561 | Irwan +6019 2787719*
*Email: corporateaffairs@maybank.com*

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់៖

នាយកដ្ឋានកិច្ចការក្រុមហ៊ុនរបស់សម្ព័ន្ធធនាគារ មេយប៊ែង

*Izlyn Ramli +60 19 200 0248/Wan Nazdy +6012 3517561 | Irwan +6019 2787719*
*Email: corporateaffairs@maybank.com*